# ឧទ្ធរណ៍ព្រះរាជាណាចក្រកម្ពុជា

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៩៨

ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០

សាលដីកា

លេខ: ២៥៦

ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៦៧“ខ” ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៩៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់តុលាការកំពូល។

<u>ពីបទ:</u> បង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ បច្ចុប្បន្ននៅក្រៅឃុំ

១-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរត់តាក់ស៊ី កើតនៅភូមិវត្តកណ្តាល ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ ទីលំនៅសព្វថ្ងៃភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង។

២-ជនជាប់ចោទឈ្មោះ[redacted](ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤១ឆ្នាំ ជាតិឥស្លាម កើតនៅភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង។



Scanned by CamScanner

៣-ជនជាប់ចោទឈ្[redacted]ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិ ផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

៤-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបររៀនកែសម្ផស្ស កើតនៅភូមិចំការសំរោង ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

៥-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ៣២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វាយប៉ោ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

<u>ពីបទ:</u> បង្ករបួសស្នាមដោយចេតនាមានអាវុធ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១, ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៨ នៃច្បាប់ស្តានទម្ងន់ទោស។ បច្ចុប្បន្ននៅក្រៅឃុំ

៦-ជនជាប់ចោទឈ្[redacted]ហៅ[redacted]ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរជាងមាស និងរត់ម៉ូតូឌុប កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅ សព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

៧-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ មុខរបរជាងម៉ាស៊ីន កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

៨-ជនជាប់ចោទឈ្មោ[redacted]ភេទស្រី ជាតិខ្មែរឥស្លាម មុខរបរគ្មាន កើតនៅភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

៩-ជនជាប់ចោទឈ្មោ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងក្លែម កើតនៅភូមិព្រៃដាច់ ឃុំអូរពាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

១០-ជនជាប់ចោទឈ្មោ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរគ្មាន កើតនៅភូមិនរា ឃុំនរា ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ

ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

-កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ម៉ោង២២និង៣០នាទី នៅចំណុចវាលស្រែ១០០០ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានការជេរប្រមាថ វាយតប់គ្នា រវាងគ្រួសារ[redacted]ប្រពន្ធឈ្មោះ[redacted]កូនស្រី[redacted] និងអ្នកផ្សេងទៀត ម្ចាស់ហាងលក់គ្រឿងក្លែម និងខាវ៉ាអូខេ (អំពិលទឹកផ្អែក) ជាមួយគ្រួសារ[redacted]ហៅ[redacted] ប្រពន្ធ[redacted]ហៅ[redacted]ហៅ[redacted] នៅក្នុងផ្ទះ[redacted] លក់គ្រឿងក្លែមទល់មុខគ្នា។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបងថា: ចោទប្រកាន់លើ១-ឈ្មោះ[redacted]ភេទប្រុស អាយុ៤៦ឆ្នាំ ២-ឈ្មោះ[redacted]ភេទស្រី អាយុ៤១ឆ្នាំ ៣-ឈ្មោះ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ៤-ឈ្មោះ[redacted]ភេទស្រី អាយុ២២ឆ្នាំ ៥-ឈ្មោះ[redacted] ភេទស្រី អាយុ១៩ឆ្នាំ ៦-ឈ្មោះ [redacted]ភេទស្រី អាយុ៣២ឆ្នាំ ៧-ឈ្មោះ[redacted] ហៅ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ៨-ឈ្មោះ[redacted]ភេទស្រី អាយុ២២ឆ្នាំ ៩-ឈ្មោះ[redacted] ភេទស្រី អាយុ១៨ឆ្នាំ ១០-ឈ្មោះ[redacted]ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ: បង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្ដន្ទាទោសតាមមាត្រា ៤១, ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤២"ឃ" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចៈ

១-ឱ្យជនជាប់ចោទឈ្មោះ៖

[redacted]ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ។

ខ[redacted]ភេទស្រី អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ។

គ-[redacted]ភេទស្រី អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ។

ឃ-[redacted]ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ។

ង-[redacted]ហៅ[redacted]ភេទស្រី អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ។

រួចផុតពីបទ: ជេរប្រមាថ ប្រព្រឹត្តនៅចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលចោទប្រកាន់តាមដីកាសន្និដ្ឋានលេខ ២៨៦ ដសសព ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង និងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ១០៣២ សពព្រទចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ចៅក្រម



Scanned by CamScanner

ស៊ើបអង្កេតថៃតុលាការខេត្តបាត់ដំបង។ តាមមាត្រា៣៨ វាក្យខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

២-ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.[redacted]ភេទស្រី អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៣ខែ (បីខែគត់) និងកែប្រែទោសព្យួរ ១០ខែ (ដប់ខែ) តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ៤០"ច" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការខេត្តបាត់ដំបង ទៅជាទោសដាក់ពន្ធនាគារ។ សរុបទោស គឺដាក់ពន្ធនាគារសរុប១៣ខែ (ដប់បីខែគត់) គិតពីថ្ងៃទទួលរងទោសក្នុងពន្ធនាគារ។

ខ[redacted] ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៦ខែ (ប្រាំមួយខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

គ[redacted] ភេទស្រី អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

ឃ[redacted]ភេទស្រី អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៣ខែ (បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

ង[redacted]ហៅ[redacted]ភេទស្រី អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។ រយៈពេលសាកល្បង៥ឆ្នាំគត់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។ ពីបទៈបង្ករបួសស្នាមដោយចេតនាមានអាវុធ។

៣-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ៖

ក[redacted]ហៅ [redacted]ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុប ៦ខែ (ប្រាំមួយខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

ខ[redacted] ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

គ[redacted]ភេទស្រី អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

ឃ[redacted]ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៣ខែ (បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ។

ង[redacted] ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារសរុប៣ខែ (បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួររយៈពេលសាកល្បង៥ឆ្នាំ គត់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

ពីបទៈ បង្ករបួសស្នាមដោយចេតនាមានអាវុធ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤។



Scanned by CamScanner

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១ និង៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម្ចាស់សងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តសរុប ២.០០០.០០០៛ (ពីរលានរៀលគត់) ទៅឱ្យខាង [redacted] បណ្តឹងទាមទារលើសពីនេះត្រូវបដិសេធចោល។

៥-ពេលសាលក្រមចូលជាស្ថាពរ បើជនជាប់ចោទឈ្មោះ [redacted] និង [redacted] រឹងរូសពុំព្រមបង់ប្រាក់សំណងចំនួន ២.០០០.០០០ ទៅឱ្យដើមបណ្តឹងឈ្មោះ [redacted] ទនោះត្រូវដាក់គុកបង្ខំដល់រូបកាយក្នុងម្នាក់ៗពីរឆ្នាំ ដើម្បីបង្ខំទារប្រាក់ធនទណ្ឌតាមមាត្រា៧ និង៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាយកាយក្នុងរឿងព្រហ្មទណ្ឌ។

៦-សាលក្រមនេះ ជំនុំជម្រះចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទ [redacted] និង [redacted] បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨៤ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤២"ឃ" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ របស់ សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី២-ក និងចំណុចទី៤ នៃការវិនិច្ឆ័យសេចក្តីទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: សាលក្រមព្រហ្មទណ្ឌលេខ៤២"ឃ"ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ បានសម្រេចសេចក្តី លើករណីរបស់ឈ្មោះ ស៊ីម រ៉ា ដោយដាក់គុក៣ខែ ពីបទ: បង្ករបួសស្នាម ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ រួចកែប្រែទោសព្យួរក្នុងសាលក្រមព្រហ្មទណ្ឌលេខ៤០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ពី១០ខែ ព្យួរមកជា១០ខែគត់វិញនោះ គឺជាការភ័ន្តច្រឡំដ៏ធ្ងន់ធ្ងរដែលគប្បីសភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍បដិសេធសាលក្រមនេះចោលត្រង់ចំណុច២-ក រួចកែតម្រូវឡើងវិញ ដោយចាត់ទុកថា ការប្រព្រឹត្តរបស់ឈ្មោះ [redacted] ជាការមិនរាងចាលប្រព្រឹត្តច្រំដែល ដែលគប្បីដាក់ទោសគុកតាមស្ថានទម្ងន់វិញ។

-ការប្តឹងឧទ្ធរណ៍ ពីសំណងរដ្ឋប្បវេណីត្រង់ចំណុច៤ នៃសាលក្រមមហាអយ្យការសូមឱ្យសភាព្រហ្មទណ្ឌសម្រេចតាមមាត្រា៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌតទៅ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៧"ខ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៨៤ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ របស់ជនជាប់ចោទ ស៊ីម រ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់ចំណុចទី២ "ក" និងទី៤ នៃសាលក្រមព្រហ្មទណ្ឌលេខ៤២ "ឃ" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ ទុកជាបានការដដែល។



Scanned by CamScanner

-លុបវិធានអនុវត្តចេញពីការប្រកាសនៃសាលក្រម។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹង បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីពេលនេះតទៅ។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៤៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៦៧"ខ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញសារណាការពារចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

-ទទួលបណ្ដឹងសាទុក្ខលេខ១៤៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]កជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៦៧"ខ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍។

សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សារណាការពាររបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៤៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ[redacted]ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន យោងតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលម្ចាស់បណ្ដឹងសាទុក្ខជាជនជាប់ចោទឈ្មោ[redacted]ងសាទុក្ខមកតុលាការកំពូល ដើម្បីឲ្យពិនិត្យអំពីឧត្ដិភាពនៃបទល្មើស និងពិរុទ្ធភាពរបស់ខ្លួននោះ តុលាការកំពូលមិនអាចពិចារណាបានឡើយ ព្រោះថាមានភស្តុតាងដាក់បន្ទុកធ្ងន់ធ្ងរដូចជា ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted]ុងសារណាការពារចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ ដែលបានដាក់ជូនមកតុលាការកំពូល គឺខ្លួនមកនេះបញ្ជាក់ថា នាពេលកើតហេតុនោះ មានការប្រតាយប្រតប់គ្នាមែន



Scanned by CamScanner

ដែលតាមរយៈភស្តុតាងទាំងនេះ អាចបញ្ជាក់អំពីអត្ថិភាព នៃបទល្មើសបង្ករបួសដោយចេតនា ដូចដែលតុលាការអង្គហេតុទទួលស្គាល់ហើយ។ 2

-យល់ឃើញថា ការដែលតុលាការអង្គហេតុបានប្រកាសទោសលើជនជាប់ចោទឈ្មោះ[redacted] ដាក់ពន្ធនាគារ៣ខែ ក្នុងអង្គហេតុខាងលើ និងធ្វើការកែប្រែទោសពន្ធនាគារ១០ខែ ជាទោសព្យួរក្នុងសាលក្រមព្រហ្មទណ្ឌលេខ៤០"ឆ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ដោយសំអាងថា ជនជាប់ចោទប្រព្រឹត្តបទល្មើសក្នុងរយៈពេលសាកល្បង នោះការសម្រេចអំពីការដកហូតការព្យួរទោសបែបនេះមិនទាន់មានការសំអាងហេតុគ្រប់គ្រាន់នៅឡើយទេ ព្រោះថាតាមស្មារតីមាត្រា៣ (គោលការណ៍នីត្យានុកូលភាព) កឋាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចែងថា "មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន" ឯមាត្រា៥ នៃក្រមដដែលកំណត់ថា ការបកស្រាយច្បាប់ព្រហ្មទណ្ឌត្រូវមានភាពតឹងរ៉ឹង។ ករណីនេះតុលាការអង្គហេតុមិនទាន់បានបង្ហាញអំពីសំអាងហេតុទាក់ទិននឹងបញ្ញត្តិព្រហ្មទណ្ឌ ណាមួយអនុញ្ញាតឱ្យធ្វើការដកហូតទោសព្យួរ ក្នុងនីតិវិធីនៃការប្រកាសដកហូតទោសព្យួរនោះទេ។ ដូច្នេះភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុ យោងតាមស្មារតីមាត្រា៤១៩ ចំណុចទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអង្គហេតុគប្បីពិចារណាជាថ្មី កុំឱ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាពនៃទោស នៃច្បាប់ព្រហ្មទណ្ឌ។

-យល់ឃើញថា គូភាគីត្រូវបានកោះហៅត្រឹមត្រូវហើយ តែមិនបានចូលរួមសវនាការនាពេលនេះទេ តែភាគីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាហើយ។ ដូច្នេះតាមស្មារតីមាត្រា៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌតុលាការកំពូលអាចជំនុំជម្រះបាន។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៧"ខ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះត្រឹមត្រូវហើយ លើកលែងតែចំណុចស្តីពីការដកហូតទោសព្យួរក្នុងចំណុចទី២ (ក) នៃសាលក្រមលេខ៤២"ឃ" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងខេត្តបាត់ដំបង ខុសនឹងគតិច្បាប់។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ទទួលផ្នែកខ្លះ និងបដិសេធផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ១៤៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ[redacted]

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៧"ខ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចស្តីពីការដកហូតទោសព្យួរ ក្នុងចំណុចទី២ (ក) នៃសាលក្រមលេខ៤២"ឃ" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងខេត្តបាត់ដំបង ត្រូវបដិសេធចោល។



Scanned by CamScanner

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៩៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មី អំពីចំណុចខាងលើ។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១១ ខែតុលា និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner